ការភ័យបាក់ស្បាតជាផលវិបាកដែលកើតមានចំពោះអ្នករងគ្រោះ បន្ទាប់ពីបានឆ្លងកាត់ ឬ ជួបប្រទះដោយបានឃើញដោយផ្ទាល់ភ្នែក ឬ ត្រូវប្រឈមមុខជាមួយនិងព្រឹត្តិការណ៍ធ្ងន់ធ្ងរណាមួយ ឬ ច្រើននៅក្នុងឆាកជីវិត ដែលបានយាយី ឬ គំរាមកំហែងចំពោះអាយុជីវិតរបស់អ្នករងគ្រោះ។

## ប្រភេទ និង មូលហេតុ

ព្រឹត្តិការណ៍ធ្ងន់ធ្ងរៗនិងគ្រោះមហន្តរាយដែលកើតឡើងដោយបណ្តាលមកពីការប្រែប្រួលរបស់ធម្មជាតិ ហើយនិងមួយចំណែកទៀតដោយសារស្នាដៃមនុស្សលោកដែលបង្កើតទៅជាមហន្តរាយចំពោះសង្គមរស់នៅ។ ព្រឹត្តិការណ៍ទាំងនោះអាចរាប់បញ្ចូលដូចជា៖ ទឹកជំនន់ អគ្គិភ័យ រញ្ជួយផែនដី ព្យុះសង្ឃរា គ្រោះថ្នាក់ចរាចរ ចំណាប់ជីវិតយកលុយ បានឃើញការកាប់សម្លាប់ ការប្លន់ ការចាប់រំលោភរាងកាយ ការភៀសខ្លួន ឬ ចលាចលនៅក្នុងសង្គម គ្រោះថ្នាក់ក្នុងការរត់គេចខ្លួន ការរស់នៅក្នុងជំរំជនភៀសខ្លួន ទទួលទារុណកម្ម ជាប់ឃុំឃាំង ជាដើម។ អ្នកដែលនៅមានជីវិតរស់រានបន្ទាប់ពីបានឆ្លងកាត់ហេតុការណ៍ណាមួយ ឬ ច្រើន ដែលបានបញ្ជាក់ពីមុននេះ អាចបង្កើតឲ្យមានការភ័យបាក់ស្បាតសំរាប់អ្នករងគ្រោះក្នុងការបន្តការនៅរបស់គេ។

## ផលវិបាក

ការភ័យបាក់ស្បាតអាចបង្កើតឲ្យមានផលវិបាកជាច្រើនប្រការសំរាប់អ្នករងគ្រោះដែលនៅមានជីវិតបន្ទាប់ពីបានឆ្លងកាត់នូវព្រឹត្តិការណ៍ទាំងឡាយដ៏កាចសាហាវនិងជាទីភ័យតក់ស្លត់បំផុត។ វាអាចធ្វើឲ្យអ្នករងគ្រោះបាត់បង់នូវលទ្ធភាព និង សមត្ថភាពក្នុងការប្រកបការងារ ឬ កិច្ចការប្រចាំថ្ងៃ ដែលយើងតែងតែធ្វើពីមុនមក។ អ្នករងគ្រោះអាចបង្ហាញឲ្យឃើញមានការប្រែប្រួលខ្លះនូវអត្តចរិត និង ចរិយានិងឥរិយាបថដែលមានពីមុនមក។ លក្ខណៈប្រែប្រួលនេះអាចមាន នៅក្នុងសភាពបន្តិចបន្តួច ឬ ស្រាល នៅពេលដែលអ្នករងគ្រោះនៅមានលទ្ធភាពអាចទ្រាំទ្រ និង ទប់ទល់ជាមួយនិងផលវិបាកនៃការ ភ័យបាក់ស្បាត។ លក្ខណៈនៅក្នុងកំរិតនេះអ្នកដទៃមិនទាន់អាច សំគាល់និងសង្កេតដឹងនៅឡើយទេ ថ្វីត្បិតតែមានការចាប់អារម្មណ៍អំពីសមាជិកគ្រួសាររបស់អ្នករងគ្រោះក៏ដោយ។ ពីព្រោះអ្នករងគ្រោះនៅមានសកម្មភាពក្នុងសភាពធម្មតាបានក្នុងការកសាងជីវិតថ្មីរបស់គេ។ នៅពេលដែលលក្ខណៈប្រែប្រួលមានសភាពខ្លាំង វាអាចធ្វើឲ្យមានការផ្លាស់ប្តូរនូវអត្តចរិត និង ចរិយានិងឥរិយាបថរបស់អ្នករងគ្រោះ ដែលបង្ហាញនិងបញ្ជាក់អំពីសភាពធ្ងន់ធ្ងររបស់អាការៈរោគ។ លក្ខណៈនេះវាអាចធ្វើឲ្យបាត់បង់នូវលទ្ធភាពទ្រាំទ្រ និង ទប់ទល់ ជាមួយនិងផលវិបាកនៃការបាក់ស្បាត។ផលវិបាកនេះអាច បង្កើតឲ្យមានលក្ខណៈប្រែប្រួល ផ្នែកខាងរាងកាយ ផ្នែកខាងផ្លូវចិត្ត និង ផ្នែកខាងលទ្ធភាពប្រាស្រ័យទាក់ទងនៅក្នុងសង្គម សំរាប់អ្នករងគ្រោះ។

### ក - ផ្នែកខាងរាងកាយ

ផលវិបាកដែលអាចមាននៅលើរាងកាយរបស់អ្នករងគ្រោះមាន ដូចជា៖ ស្លាកស្នាមឬសនៃទារុណកម្ម ពិការអវយវៈ ដូចជា ខ្វិន ជើង ខូចដៃ ខ្វាក់ភ្នែក ខូចក្រពះនោម ថ្លង់ ជាដើម បង្កើតជម្ងឺរាំរ៉ៃ ដូចជា ការខូចដំរងនោម ខូចប្រដាប់បន្តពូជ រលាកស្បូត ខូចខួរ ក្បាល ឈឺសន្លាក់ ឈឺពោះចុកចាប់សាច់ដុំ ឈឺក្បាល ពេតទឹកនោមផ្អែម ពិបាកគេង បាត់បង់រសជាតិអាហារឬមិនចង់ញ៉ាំ ។ល។

### ខ - ផ្នែកខាងផ្លូវចិត្ត

ចំពោះផលវិបាកដែលអាចធ្វើឲ្យមានការប្រែប្រួលផ្នែកខាងផ្លូវចិត្តមានដូចជា៖ ការឆាប់ម៉ួរម៉ៅ ឬ ខឹងច្រើន ឆាប់ភ្លេចភ្លាំង យល់សប្តិជារឿយៗនូវរឿងអំពីអតីតកាល ឬ អំពីស្រុកកំណើត មិនសប្បាយចិត្តនៅនឹកឃើញតែការសោកសៅអំពីការរងទុក្ខវេទនាពីមុនមក មិនចង់ឮគេនិយាយអំពីរឿងដែលធ្លាប់បានជួបលំបាកពីមុនមក មិនចង់មើលឬស្តាប់រឿងកំសត់ ឬ លំបាក ការជក់ជាប់នូវការគិតអំពីព្រឹត្តិការណ៍សោកសៅជានិច្ច មានការលំបាកក្នុងការផ្ចង់ស្មារតី ឆាប់ភ័យខ្លាចជាពិសេសជាមួយរដ្ឋបាលដែលប្រើឯកសណ្ឋានដូចជា នគរបាល ទាហ៊ាន បុគ្គលិកពេទ្យ ជាដើម។

### គ - លទ្ធភាពប្រាស្រ័យទាក់ទងក្នុងសង្គម

ការប្រែប្រួលនៅក្នុងលក្ខណៈនេះបញ្ជាក់នូវភាពផ្លាស់ប្តូរលទ្ធភាពប្រាស្រ័យទាក់ទងក្នុងសង្គមរបស់រងគ្រោះដែលមានផលវិបាកតាំងពីកំរិតការទាក់ទងផ្ទាល់ខ្លួន រហូតដល់ការប្រាស្រ័យទាក់ទងជាក្រុម និង នៅក្នុងសង្គមទៀតផង។ នៅពេលខ្លះមិត្តភ័ក្តិ បងប្អូនអាចសង្កេតឃើញនូវភាពប្រែប្រួលខាងអត្តចរិតរបស់អ្នករងគ្រោះ។

ការប្រែប្រួលមានលក្ខណៈពីរយ៉ាង៖ ចរិយានិងឥរិយាបថ និង ទំនាក់ទំនង ផ្ទាល់ខ្លួន។

#### ១-ចរិយានិងឥរិយាបថ

ការប្រែប្រួលផ្នែកចរិយានិងឥរិយាបថអាចបង្ហាញនូវកាយវិការឃោឃៅ សកម្មភាពចង់សម្លាប់ខ្លួន ឬ គ្រោះដល់ខ្លួន សេពសុរាហួសប្រមាណ ឬ ការប្រើគ្រឿងញៀន ទិតទំជៀសវាងនូវសកម្មភាពដែលអាចនាំឲ្យរំលឹកអំពីការជួបប្រទះនៅក្នុងឆាកជីវិតកន្លងមកហើយ បាត់បង់សមត្ថភាពចូលរួមសកម្មភាពនៅក្នុងសង្គម ទំជៀសវាង ឬ លាក់ខ្លួននៅដោយឡែកពីគេ ហើយនិង ឆាប់ភ័យខ្លាចជាច្រើន។ល។

#### ២-ទំនាក់ទំនងផ្ទាល់ខ្លួន

ការប្រែប្រួលនៅក្នុងលក្ខណៈនេះអាចរាប់បញ្ចូលនូវសកម្មភាពទាំងឡាយ ដែលត្រូវបំពេញសំរាប់សេចក្តីត្រូវការជាទំនាក់ទំនងផ្ទាល់ខ្លួនដូចជា មានការលំបាក ឬ បញ្ហាចោទចំពោះការរួមដំណេក ឬ រួមមេត្រីភាព បញ្ហាចោទផ្នែកទំនាក់ទំនងនៅក្នុងគ្រួសារ ឬ រវាងគ្រួសារ បន្តភាពរងគ្រោះនៅក្នុងស្ថានភាពលំបាក អ្នករងគ្រោះអាចក្លាយទៅជាអ្នកបង្កើតការរងគ្រោះ។

## លក្ខណៈរោគសញ្ញា

ការសំគាល់ ឬ បញ្ជាក់អំពីលក្ខណៈរោគសញ្ញានៃការភ័យបាក់ស្បាតដោយគ្មានការពិនិត្យ និង វិនិច្ឆ័យអំពីអ្នកជំនាញការ និង ពិសោធន៍ផ្នែកខាងជម្ងឺនេះ ប្រាកដជាមិនមែនជាការងាយស្រួល ហើយក៏មិនបានត្រឹមត្រូវផងដែរ។ ពីព្រោះអ្នករងគ្រោះខ្លះនៅមានលទ្ធភាពអាចទ្រាំទ្រជាមួយនិងផលវិបាកនៃការភ័យបាក់ស្បាត ដោយអាចនៅបន្តសកម្មភាពប្រក្រតីឲ្យស្ថិតនៅក្នុងសភាពធម្មតាដែលបងប្អូន មិត្តភ័ក្តិ ស្វាមី ឬ ភរិយា មិនអាចសង្កេតបានថា មានជម្ងឺផ្នែកខាងការភ័យបាក់ស្បាតបានទេ។ លក្ខណៈទូទៅខ្លះៗដែលអាចជួយអ្នករងគ្រោះឲ្យសង្កេតដឹងដោយខ្លួនឯងបានដូចជា៖ ការយល់សប្តិជារឿយៗអំពីរឿងអតីតកាល ឃើញរឿងអតីតកាលដូចជានៅថ្មីៗជាប់ជានិច្ច ម៉ួរម៉ៅមិនសប្បាយចិត្តអំពីរឿងកន្លងមកហើយនៅក្នុងជីវិត ឆាប់ភ័យខ្លាចជាមួយអ្នកស្លៀកពាក់ឯកសណ្ឋានជាដើម។ល។